# មន្ទីរកសិកម្មខេត្តកណ្តាល

# ដំណាំម្ទេស




អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)



ឧបត្ថម្ភដោយ: អង្គការវីវីអូប៊ី VVOB

vvob education for development

ឆ្នាំ ២០១០


# ដំណាំម្ទេស

## ១. លក្ខណៈទូទៅ

ដំណាំម្ទេស គឺត្រូវបានគេទទួលស្គាល់ និងពេញនិយមប្រើប្រាស់ជាយូរយារណាស់មកហើយ។ លក្ខណៈពិសេសរបស់ម្ទេសគឺមានរសជាតិហឹរ ពេលទុំមានពណ៌ក្រហម មានក្លិនឆ្ងួលហើយអាចលូតលាស់យូរឆ្នាំជាងពួកដំណាំក្នុងគ្រួសារដូចគ្នា។

## ២. ការជ្រើសរើសពូជ

ការជ្រើសរើសពូជត្រូវមានលក្ខណៈសម្បត្តិដូចតទៅ:

- ពូជសុទ្ធ មានប្រភពច្បាស់លាស់ និងផ្តល់ឱ្យទិន្នផលខ្ពស់
- ពូជធន់ទៅនឹងជម្ងឺ-សត្វល្អិត និងមានអាយុកាលខ្លី
- ពូជដែលមានលក្ខណៈសមស្របទៅនិងការដាំដុះ
- ពូជដែលមិនប្រកាន់រដូវ គឺអាចលូតលាស់បានគ្រប់រដូវ
- ពូជមានគុណភាពល្អ និងមានដំណុះខ្ពស់លើស ៨៥%

## ៣. ការជ្រើសរើសពេលវេលាដាំដុះ

ពេលវេលាសមស្របសំរាប់ការដាំដុះម្ទេស គឺមានពីរ:

- ចំពោះតំបន់លិចទឹក គឺចាប់ផ្តើមពីខែ តុលា ដល់ខែមិនា ហើយពន្យាពេលប្រមូលផលរហូតដល់ខែកក្កដា ឬសីហា
- ចំពោះតំបន់មិនលិចទឹក គឺចាប់ផ្តើមពីខែមិថុនា ឬខែកក្កដា ហើយធ្វើការប្រមូលផលបញ្ចប់នៅខែវិច្ឆិកា ឬធ្នូ។

## ៤. ការជ្រើសរើស និងរៀបចំដី

**ការជ្រើសរើសដី**

- ដីមានជីជាតិល្អ នៅក្បែរប្រភពទឹក
- ដីល្បាប់ល្បាយខ្សាច់ ធូរ សម្បូរទៅដោយជាតិមមោគ និងសារធាតុចិញ្ចឹមខ្ពស់
- ជៀសវាងការជ្រើសរើសដីដែលដាំម្ទេសយូរឆ្នាំ ឬពពួកគ្រួសារតែមួយដូចជាប៉េងបោះ ត្រប់......។

**ការរៀបចំដី**

ការរៀបចំដីមានសារៈសំខាន់ណាស់ ព្រោះវាជួយធ្វើឱ្យដីធូរមានខ្យល់ចេញចូលគ្រប់គ្រាន់ និងរក្សាសំណើមដីបានល្អ ព្រមទាំងជួយធ្វើឱ្យមានលំនឹង ពពួកបាក់តេរីមានប្រយោជន៍ ដោយត្រឡប់ពីលើចុះក្រោម និងពីក្រោមឡើងលើ។

ការភ្ជួរឱ្យបានជ្រៅ គឺធានាដល់ការចាក់ឬសរបស់ដំណាំ ព្រោះឬស គឺជាប្រព័ន្ធមួយសំរាប់ជួយដល់រុក្ខជាតិក្នុងការជញ្ជូនយកសារធាតុចិញ្ចឹម និងទឹកទៅផ្នែកសរីរាង្គដទៃទៀត។

ក្រៅពីភ្ជួរឱ្យបានជ្រៅ ដីត្រូវរាស់ឱ្យបានហ្មត់ល្អ និងកៀរឱ្យបានរាបស្មើ ដោយប្រមូលយកកំទេចកំទីរុក្ខជាតិដែលនៅសេសសល់ពីរដូវមុន រួមជាមួយស្មៅចង្រៃចេញ។

**ការលើករង**

ក្រោយពីរៀបចំដីរួចហើយ គេត្រូវលើករងឱ្យបានខ្ពស់គឺពី ២០-៣០សង្ទីម៉ែត្រ (អាស្រ័យទៅតាមតំបន់លិចទឹក ឬមិនលិចទឹក) ទទឹងរងអាស្រ័យលើវិធីសាស្រ្តដាំដុះ(បើដាំមួយជួរ ទទឹងរងគឺ ៦០-៨០សង្ទីម៉ែត្រ បើដាំពីរជួរ ទទឹងរង គឺ ១០០-១២០ សង្ទីម៉ែត្រ) រីឯបណ្តោយគឺអាស្រ័យទៅតាមលទ្ធភាពជាក់ស្តែងរបស់ដី។

## ៥. បច្ចេកទេសដាំដុះ

ដំណាំម្ទេសអាចដាំដុះដោយការបណ្តុះកូនដូចជាត្រប់ និងប៉េងបោះដែរ។

**ការបណ្តុះកូន**

គេអាចសាបកូនដោយគ្រាន់តែយកគ្រាប់ពូជទៅសាបលើថ្នាលផ្ទាល់ រហូតដល់វាមានអាយុ ៣៥-៤០ថ្ងៃ ពោលគឺមានស្លឹក ៣-៤ ទើបយកទៅដាំ។ តែដើម្បីឱ្យកូនម្ទេសលូតលាស់